មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្លេងយុត្តិធម៌: អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

## កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា
## ការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម
## និងសំណុំរឿង០០២នៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

## វគ្គទី២

## ប្រធានបទ: ការអត់ឃ្លាន និងការស្លាប់ហួសប្រមាណនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

*ដោយ : រ៉េនឌល ឌីហ្វាល់កូ*

*ជាមួយនឹង ម៉ែន ពិចិត្រ និង លន់ ដាលីន*

*អានដោយ : ឌី ខាំបូលី និង កន ពេញសំណាង*

*សហការជាមួយបន្ទប់ថតសម្លេងរបស់ស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ*

*ខែមេសា ឆ្នាំ២០១៣*

*ជម្រាបសួរប្រិយមិត្តអ្នកស្តាប់វិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាទីមេត្រី នេះគឺជាការផ្សាយវគ្គទី២នៃកម្មវិធីវិទ្យុរបស់យើងខ្ញុំដែលពិនិត្យពិច័យទៅលើប្រវត្តិ និងទិដ្ឋភាពច្បាប់ទាក់ទងនឹងការអត់ឃ្លានដែលបានកើតឡើងនៅប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហមចន្លោះពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ។ កម្មវិធីវិទ្យុនេះមានគោលបំណងផ្សព្វផ្សាយឲ្យប្រជាជនកម្ពុជាទាំងអស់បានដឹងការពិតអំពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់ជនរងគ្រោះពាក់ព័ន្ធទៅនឹងការអត់ឃ្លាន និងជំរុញឲ្យមានការចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិធម៌ ។ កម្មវិធីរបស់យើងខ្ញុំចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យ ។ វគ្គនីមួយៗនឹងត្រូវចាក់ផ្សាយចំនួនបួនដងក្នុងមួយខែ ។ រៀងរាល់ដើមខែ យើងខ្ញុំនឹងលើកយកវគ្គថ្មីមកចាក់ផ្សាយ ។ ប្រិយ-មិត្តដែលរស់នៅរាជធានីភ្នំពេញ និងខេត្តដែលនៅជាប់នឹងរាជធានីភ្នំពេញអាចស្តាប់កម្មវិធីវិទ្យុសហ-គមន៍របស់យើងខ្ញុំ តាមរយៈវិទ្យុជាតិកម្ពុជា*AM918 KHz *រាជធានីភ្នំពេញ វេលាម៉ោង ៩ព្រឹក និង*

ម៉ោង៧និង៣០នាទីល្ងាច ។ នៅខេត្តកំពត តាមរយៈវិទ្យុខេត្តកំពត FM93.25 វេលាម៉ោង៧ព្រឹក និង ម៉ោង៧ល្ងាច ។ នៅខេត្តព្រះវិហារ តាមរយៈវិទ្យុខេត្តព្រះវិហារ FM99 វេលាម៉ោង៧និង៣០នាទីព្រឹក និងម៉ោង៤រសៀល ។ នៅខេត្តបាត់ដំបង តាមរយៈវិទ្យុខេត្ត បាត់ដំបង FM103.25 វេលាម៉ោង ៨ព្រឹក និងម៉ោង៤រសៀល ។

ការផ្សាយវគ្គទីពីរនេះ ផ្តោតទៅលើប្រវត្តិដើមដំបូងនៃការធ្វើឲ្យមានការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ទស្សនៈផ្សេងៗអំពីមូលហេតុដែលបណ្តាលឲ្យមានការស្លាប់ហួសប្រមាណ ក៏ដូចជាហេតុផលមួយចំនួនដែលអ្នកស្រាវជ្រាវជាច្រើនមានការពិបាកក្នុងការកំណត់ថា តើមានប្រជាជនចំនួនប៉ុន្មាននាក់ដែលបានស្លាប់ដោយសារការអត់ឃ្លាននៅក្នុងប្រទេសកម្ពុជាចន្លោះពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។

មុននឹងយើងចាប់ផ្តើមបទអត្ថាធិប្បាយវគ្គពីរនេះ យើងខ្ញុំសូមជម្រាបជូនប្រិយមិត្តអ្នកស្តាប់អំពីការវិវឌ្ឍរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ រយៈពេលថ្មីៗកន្លងមកនេះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានចេញសេចក្តីសម្រេចបដិសេធ ការបំបែកសំណុំរឿង០០២ទៅជាសំណុំរឿងតូចៗ ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់មូលហេតុសមរម្យ ក្នុងការសម្រេចបំបែកសំណុំរឿង០០២ទៅជាសំណុំរឿងតូចៗនោះទេ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងកំពុងផ្តោតទៅលើតែរចនាសម្ព័ន្ធដឹកនាំនៅក្នុងរបបខ្មែរក្រហម និងឧក្រិដ្ឋកម្មទាំងឡាយដែលកើតឡើងដោយសារការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននានា ។ បច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងកំពុងដំណើរការកាត់សេចក្តីលើសំណុំរឿងមួយចេញពីសំណុំរឿង០០២ ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការសម្រេចចិត្តបំបែកសំណុំរឿងរបស់ខ្លួនមានសារៈសំខាន់ចំពោះភាគីទាំងអស់នៅក្នុងសំណុំរឿង ។ ទន្ទឹមនឹងគ្នានេះដែរ សហព្រះរាជអាជ្ញា បានស្នើសុំអង្គជំនុំជម្រះសាលាដំបូងបញ្ចូលបទចោទប្រកាន់ទាក់ទងនឹងគុកទួលស្លែងទៅក្នុងសំណុំរឿងតូចនេះ ។ ប៉ុន្តែ មេធាវីការពារជនជាប់ចោទបានបដិសេធរាល់ការបញ្ចូលបទចោទប្រកាន់បន្ថែមទៅក្នុងសំណុំរឿងតូចនៃសំណុំរឿង០០២ ។ ជាងនេះទៅទៀត ការសម្រេចចិត្តបំបែកសំណុំរឿង០០២ទៅជាសំណុំរឿងតូចៗ បានបំពាល់ដល់ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតដែលសំណុំរឿងរបស់ខ្លួនមិនមានការពាក់ព័ន្ធទៅនឹងសំណុំរឿងតូចនៃសំណុំរឿង០០២ ដែលកំពុងដំណើរការសព្វថ្ងៃ ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលសំណុំរឿងរបស់ខ្លួនមិនមានការពាក់ព័ន្ធនឹងសំណុំរឿងតូចនេះ ត្រូវរង់ចាំទំរាំដល់ការជំនុំជម្រះក្តីលើសំណុំរឿងថ្មីដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលខ្លួនស្នើសុំចូល

រួម ចាប់ផ្ដើមដំណើរការ ។ ស្របពេលនឹងគ្នានេះដែរ សុខភាពរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ កំពុងតែស្ថិតក្នុងស្ថានភាពដែលគួរឲ្យព្រួយបារម្ភ ។ កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ អៀង សារី ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបខ្មែរក្រហមបានស្លាប់នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដោយសារជម្ងឺ ។

## សេចក្ដីផ្ដើមៈ ខ្មែរក្រហម និងការសន្យាថាប្រជាជនគ្រប់រូបមានអាហារបរិភោគគ្រប់គ្រាន់

ស្រូវ ឬអង្ករ គឺជាប្រភេទចំណីអាហារដ៏សំខាន់មួយសម្រាប់ប្រជាជនកម្ពុជា ។ ដូច្នេះ នៅក្នុងកម្មវិធីវិទ្យុនេះ នៅពេលដែលនិយាយអំពីផលិតកម្មម្ហូបអាហារ គឺសំដៅលើផលិតកម្មស្រូវ ។

នៅដើមទសវត្សរ៍ឆ្នាំ១៩៦០ ផលិតកម្មស្រូវនៅក្នុងប្រទេសកម្ពុជាមានការកើនឡើងជាលំដាប់ ។ នៅចន្លោះឆ្នាំ១៩៦៣ និងឆ្នាំ១៩៦៤ ប្រទេសកម្ពុជាអាចបង្កបង្កើនផលស្រូវបានពីរដង ក្នុងមួយឆ្នាំ ហើយកម្ពុជាបាននាំផលស្រូវយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅក្រៅប្រទេស ។ ប៉ុន្តែ នៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៦០ដដែលនេះ ទោះបីជាផលិតផលស្រូវនៅក្នុងប្រទេសមានកម្រិតខ្ពស់យ៉ាងណាក៏ដោយ ក៏ការនាំចេញផលិតផលស្រូវបានធ្លាក់ចុះមកវិញ នៅពេលដែលផលិតផលស្រូវមួយចំនួនធំត្រូវបានឈ្មួញនាំចេញទៅប្រទេសវៀតណាម និងលក់ឲ្យភាគីទាំងសងខាងដែលចូលរួមនៅក្នុងសង្គ្រាមស៊ីវិល ។ ជាងនេះទៅទៀត នៅពេលដែលប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិលនៅឆ្នាំ១៩៧០ ដំណាំស្រូវទទួលការប៉ះពាល់ដោយនីកស្ថានមិនដល់ ។ ការដាំដុះ ការសាបព្រួស និងសកមភាពបង្កបង្កើនផលស្រូវមួយចំនួនមានការធ្លាក់ចុះ នៅពេលដែលមានសង្គ្រាមរវាងរដ្ឋាភិបាល លន់ នល់ ជាមួយនឹងកម្លាំងខុទ្ទាមខ្មែរក្រហម ។ ការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជានៅក្នុងរបប លន់ នល់ បានធ្វើឲ្យផលិតកម្មកសិកម្មកម្ពុជាកាន់តែថយចុះ ។ សកម្មភាពទម្លាក់គ្រាប់បែកនេះបានបំផ្លិចបំផ្លាញទីជនបទ ដីកសិកម្ម និងបានសម្លាប់ប្រជាកសិករ ព្រមទាំងសត្វពាហនៈដែលបម្រើដល់ការងារកសិកម្មអស់ជាច្រើន ។

ក្នុងអំឡុងពេលនៃសង្គ្រាមស៊ីវិល ខ្មែរក្រហមបានដឹងថាប្រជាជនកម្ពុជាដែលរស់នៅទីជនបទពឹងផ្អែកទាំងស្រុងលើផលិតកម្មកសិកម្ម ។ ខ្មែរក្រហមបានប្រកាសថា បដិវត្តន៍របស់ខ្លួននឹងនាំមកនូវរបបថ្មីមួយ ដែលផលិតកម្មកសិកម្មមានការរីកចំរើន ហើយដែលនៅពេលនោះប្រជាជនកម្ពុជានឹងមានម្ហូបអាហារគ្រប់គ្រាន់ ។ ជាឧទាហរណ៍ នៅក្នុងខ្សែភាពយន្តឃោសនាមួយរបស់ខ្មែរក្រហម ដែលថតនៅឆ្នាំ១៩៧៣ នៅខេត្តកំពង់ចាម ដែលជាតំបន់រំដោះរបស់ខ្មែរក្រហម ខៀវ សំផន ដែលជាតំណាងខ្មែរ

ក្រហម    បានដឹកនាំគណៈប្រតិភូមួយក្រុមមកពីប្រទេសវៀតណាមខាងជើងធ្វើទស្សនៈកិច្ចទៅកាន់តំបន់កសិកម្មគំរូ    ដែលបានបង្ហាញគណៈប្រតិភូទាំងនោះឲ្យឃើញថា    ប្រទេសកម្ពុជាមានផលិតកម្មស្បៀងស្ទើរគ្រប់ទីកន្លែង ។ ខណៈពេលនោះដែរ ប្រជាជននៅក្នុងសហករណ៍បានញញឹមដាក់ម៉ាស៊ីនថតខ្សែភាពយន្តនៅពេលដែលកំពុងបោកបែនស្រូវ  និងបំពេញការងារផ្សេងៗ ។  ប្រជាកសិករទាំងនោះមើលទៅដូចជាមានសុខភាពល្អ និងទទួលបានអាហារបរិភោគគ្រប់គ្រាន់ ។

ការឃោសនានេះ និងការសន្យាក្នុងការធ្វើកំណែទម្រង់ដីធ្លី ដើម្បីផ្តល់ដីបន្ថែមដល់កសិករក្រីក្រ គឺជាហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនទៀត    ដែលធ្វើឲ្យចលនារបស់ខ្មែរក្រហមមានប្រជាប្រិយភាពពីសំណាក់កសិករក្រីក្រនៅតាមទីជនបទ ។ ប្រជាប្រិយភាពនេះ និងការគ្រប់គ្រងតំបន់ផលិតស្បៀងអាហាររបស់ប្រទេសកម្ពុជា បានជួយខ្មែរក្រហមក្នុងការសម្រេចបាននូវជោគជ័យ ដោយសារខ្មែរក្រហមបានកាត់ផ្តាច់ការផ្គត់ផ្គង់ស្បៀងអាហារទៅកាន់តំបន់មួយចំនួនគ្រប់គ្រងដោយរបបលន់នល់ ។

ខ្មែរក្រហមវាយឈ្នះរដ្ឋាភិបាល លន់ នល់ និងកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។   ត្រឹមតែមួយសប្តាហ៍ប៉ុណ្ណោះ   ប្រជាជននៅទីក្រុងភ្នំពេញស្ទើរតែទាំងអស់ត្រូវបានជម្លៀសចេញពីទីក្រុង ។  ប៉ុន្តែ  មូលហេតុពិតប្រាកដនៃការជម្លៀសប្រជាជននេះ  នៅតែមានភាពស្រពេចស្រពិលមិនច្បាស់លាស់រហូតដល់សព្វថ្ងៃនេះ ។ អៀង សារី ដែលជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបខ្មែរក្រហម   បានអះអាងជាសាធារណៈថា   ការជម្លៀសដោយបង្ខំដោយមូលហេតុកង្វះស្បៀងអាហារដើម្បីចិញ្ចឹមប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់ដែលរស់នៅទីក្រុងភ្នំពេញ ។  អៀងសារី  បានបន្តថា  «បញ្ហាគឺការស្វែងរកមធ្យោបាយ  ដើម្បីដោះស្រាយបញ្ហាជីវភាពរបស់ប្រជាជនដោយប្រើប្រាស់មធ្យោបាយផ្សេងៗដែលយើងមាន ។»  អៀង  សារី  បានអះអាងទៀតថា «បញ្ហានេះបាននាំមកនូវបទពិសោធន៍យ៉ាងច្រើន   ដែលធ្វើឲ្យយើងរកឃើញមធ្យោបាយក្នុងការបង្កើនផលិតផលស្បៀង ។  ថ្វីបើបរិមាណស្រូវនៅពេលនេះមិនទាន់មានច្រើនក្រាស់ក្រែល  ប៉ុន្តែយើងមានស្រូវគ្រប់គ្រាន់ដើម្បីចិញ្ចឹមប្រជាជនគ្រប់គ្នា ។  ថ្ងៃនេះ  ប្រជាកសិករយើងកំពុងធ្វើការនៅតាមទីជនបទ ហើយបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពផលិតស្បៀងអាហារ ។»

លើសពីនេះទៅទៀត  ខៀវ  សំផន  ដែលជាប្រមុខរដ្ឋនៃរបបខ្មែរក្រហមដែលក្រោយមកត្រូវបានប្តូរឈ្មោះទៅជាកម្ពុជាប្រជាធិបតេយ្យវិញនោះ  បានអះអាងនៅក្នុងសារព័ត៌មានមួយ  ចេញផ្សាយនៅខែសីហាឆ្នាំ១៩៧៥ថា  «ទោះបីជាយើងមិនមានស្បៀងអាហារច្រើនលើសលុបក៏ដោយ  ក៏យើងនៅតែអាចចិញ្ចឹមប្រជាជនយើងបានដែរ ។»

នៅពេលដែលខ្មែរក្រហមបានកាន់កាប់ប្រទេសកម្ពុជាទាំងស្រុងហើយនោះ ខ្មែរក្រហមបានចាប់ផ្ដើមអនុវត្តនូវការសន្យារបស់ខ្លួនដែលថាប្រជាជនកម្ពុជានឹងមានអាហារបរិភោគគ្រប់គ្រាន់ ។ ប៉ុន្តែរបបថ្មីនោះមិនបានធ្វើការកសាងប្រទេសឡើងវិញឲ្យបានត្រឹមត្រូវនោះទេ ខ្មែរក្រហមបានប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសស្វយ័ត ពឹងផ្អែកលើខ្លួនឯង និងជារដ្ឋសង្គមនិយម ។ ភាពជាម្ចាស់ការ លើខ្លួនឯង និងការពន្លឿនល្បឿនហួសកម្រិត បានបង្កឲ្យមានគ្រោះអត់ឃ្លានកើតឡើងនៅក្នុងប្រទេស ដែលបានធ្វើឲ្យប្រជាជនកម្ពុជាយ៉ាងហោចណាស់ ៨សែននាក់ស្លាប់បាត់បង់ជីវិត ។ តួរលេខនេះគិតត្រឹមខែមករា ឆ្នាំ១៩៧៩ ។

*(គទៅនេះ យើងខ្ញុំសូមនាំប្រិយមិត្តអ្នកស្ដាប់ទៅពិនិត្យមើលចំណុចមួយស្ដីពី)*

## គោលនយោបាយរបស់ខ្មែរក្រហមដែលនាំឲ្យមានការអត់ឃ្លាន

បន្ទាប់ពីខ្មែរក្រហមបានឡើងកាន់អំណាច មេដឹកនាំខ្មែរក្រហមបានរៀបចំឲ្យមានការជួបប្រជុំមួយនៅទីក្រុងភ្នំពេញនៅខែឧសភាឆ្នាំ១៩៧៥ ។ នៅក្នុងកិច្ចប្រជុំនោះ គោលនយោបាយសំខាន់ៗមួយចំនួនរបស់បក្សត្រូវបានរៀបចំឡើង ដែលក្នុងនោះរួមមាន គម្រោងបង្កើតសហករណ៍ថ្នាក់ខ្ពស់ ការលុបបំបាត់ចោលរូបិយវត្ថុ រួមទាំងការបង្កើតឲ្យមានការបរិភោគ និងការរស់នៅជាសមូហភាព ។

នៅក្នុងកិច្ចប្រជុំបន្ទាប់មកទៀត ប៉ុល ពត បានធ្វើសេចក្ដីថ្លែងការណ៍មួយថាៈ

> “ប្រទេសជាតិ[យើង]ត្រូវតែកសាងឡើងវិញ ហើយលទ្ធិសង្គមនិយមត្រូវតែយកមកអនុវត្តឲ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន ។ ពោលគឺ ធ្វើយ៉ាងណាឲ្យប្រទេសកម្ពុជាដែលដើរថយក្រោយខាងផ្នែកកសិកម្ម ក្លាយទៅជាប្រទេសដែលរីកចម្រើនខាងផ្នែកកសិកម្មវិញក្នុងរយៈពេលពី៥ទៅ១០ឆ្នាំ ព្រមទាំងធ្វើការកសាងប្រទេសកម្ពុជា ពីប្រទេសដែលពឹងផ្អែកលើកសិកម្មឲ្យទៅជាប្រទេសឧស្សាហកម្មនៅក្នុងរយៈពេលពី១៥ទៅ២០ឆ្នាំខាងមុខនេះ ។»

ជាមួយគ្នានេះដែរ ខ្មែរក្រហមក៏បានប្រកាសថា ប្រទេសកម្ពុជានឹងសម្រេចឲ្យបាននូវផែនការ “មហាលោតផ្លោះមហាអស្ចារ្យ” ដែលនឹងធ្វើការកែប្រែប្រទេសឲ្យក្លាយទៅជារដ្ឋសង្គមនិយមគំរូមួយឲ្យបានលឿនបំផុត ។ មេដឹកនាំខ្មែរក្រហមបានពឹងផ្អែកទៅលើកសិកម្មដែលជាប្រភពនៃចំណូលជាតិ ដើម្បីសម្រេចទៅដល់ផែនការ“មហាលោតផ្លោះមហាអស្ចារ្យ”របស់ខ្លួន ។ នៅក្នុងកិច្ចប្រជុំមួយ ខ្មែរក្រហមបានលើកឡើងថាៈ

«យើងពឹងផ្អែកលើវិស័យកសិកម្ម ដើម្បីឈានទៅរកការសម្រេចជោគជ័យលើវិស័យផ្សេងៗទៀតដូចជា វិស័យឧស្សាហកម្ម រោងចក្រលោហៈធាតុ និងប្រេង ជាដើម ។ គន្លឹះចំបងបំផុតរបស់យើង គឺវិស័យកសិកម្ម ហើយការពឹងពាក់ខ្លួនឯង គឺជាកម្លាំងស្នូលសម្រាប់វិស័យកសិកម្ម ។»

ខ្មែរក្រហម បានដាក់គម្រោងក្នុងការបង្កើនទិន្នផលស្រូវច្រើនជាងមុន៣ដងនៃផលិតផលស្រូវដែលធ្លាប់ផលិតបាន ពោលគឺ សម្រេចឲ្យបានទិន្នផលជាមធ្យម៣តោនក្នុងមួយហិចតានៅលើដីកសិកម្មនៅទូទាំងប្រទេសកម្ពុជា ។ ប៉ុន្តែ គោលដៅនៃផលិតកម្មនេះពិបាកនឹងសម្រេចបាន ដោយមូលហេតុថា ប្រទេសកម្ពុជាមិនដែលធ្លាប់សម្រេចបានផលិតផលស្រូវក្នុងកម្រិតនេះពីមុនមកនោះទេ ។ ម្យ៉ាងវិញទៀត ប្រទេសកម្ពុជាទើបតែងើបចេញពីសង្គ្រាមស៊ីវិលដែលបានញាំញីប្រទេសអស់រយៈពេលជាង ៥ឆ្នាំមកហើយ ។

ដើម្បីសម្រេចបាននូវការបង្កើនផលិតកម្មស្រូវដ៏ច្រើនសន្ធឹកសន្ធាប់នេះ ខ្មែរក្រហមបានខិតខំដោះស្រាយបញ្ហាខ្វះខាតទឹកនៅក្នុងប្រទេស ដោយបានធ្វើការបង្កើតឲ្យមានប្រព័ន្ធប្រឡាយទឹក ទំនប់ទឹក ដើម្បីធ្វើការស្តុកទឹក និងបែងចែកទឹកឲ្យបានពេញមួយឆ្នាំ ។ ប៉ុន្តែ ខ្មែរក្រហមមិនមានថវិកា អ្នកជំនាញ និងគ្រឿងចក្រគ្រប់គ្រាន់ ដើម្បីបង្កើតប្រព័ន្ធធារាសាស្ត្រនៅទូទាំងប្រទេស ។ ផ្ទុយទៅវិញ ខ្មែរក្រហមបានពឹងផ្អែកទាំងស្រុងទៅលើកម្លាំងពលកម្មរបស់ប្រជាពលរដ្ឋ ដើម្បីកសាងទំនប់ទឹកជាច្រើន ដែលក្រោយមក ទំនប់ទឹកទាំងនោះភាគច្រើនដំណើរការមិនបានល្អ និងបាក់ខូចខាតទៅវិញ ។

ទន្ទឹមនឹងការដាក់ការងារធ្ងន់ធ្ងរ និងការបង្ខំឲ្យប្រជាជនសម្រេចឲ្យបានទិន្នផលស្រូវចំនួន ៣តោនក្នុងមួយហិតា ខ្មែរក្រហមក៏បានកាត់បន្ថយនូវរបបអាហារប្រចាំថ្ងៃរបស់ប្រជាជន ដើម្បីទុកស្រូវទៅផ្គត់ផ្គង់លើផ្នែកដទៃទៀត ។

បើតាមអ្វីដែលខ្មែរក្រហមធ្លាប់បានសន្យា ប្រជាជនកម្ពុជាត្រូវទទួលបានរបបស្រូវក្នុងម្នាក់ចំនួន ១៣ថាំង សម្រាប់រយៈពេលមួយឆ្នាំ ដែលស្មើនឹង៣១២គីឡូក្រាម ឬ ជិតមួយគីឡូក្រាមក្នុងមួយថ្ងៃ ។ ជាក់ស្តែង មានតែប្រជាជនមួយចំនួនតូចប៉ុណ្ណោះដែលទទួលបានរបបនេះ ហើយប្រជាជនភាគច្រើនទទួលបានរបបអាហារតិចតួចបំផុត ត្រឹមតែបបររាវៗមួយវែក ចំនួនពីរដងក្នុងមួយថ្ងៃ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មេដឹកនាំខ្មែរក្រហមនៅតែមានសុទិដ្ឋិនិយម និងបានប្រកាសថា នៅពេលឆាប់ៗខាងមុខនេះ ប្រជាជនទាំងអស់នឹងទទួលបានអាហារបន្ថែម នៅពេលដែលបដិវត្តន៍របស់ខ្លួនទទួលបានជោគជ័យ ។ ប្រជាជនទាំងអស់«នឹងមានការរីករាយពេញចិត្តចំពោះការរស់នៅក្នុងរបបនេះ ។» ប៉ុន្តែ អ្វីដែលគួរឲ្យសោកស្តាយនោះ គឺការសន្យារបស់ខ្មែរក្រហម មិនដែលសម្រេចបាននោះទេ ។ ជាងនេះ

ទៅទៀត ខ្មែរក្រហមបែរជាធ្វើការកាត់បន្ថយរបបអាហាររបស់ប្រជាជនបន្តិចម្តងៗ រហូតធ្វើឲ្យមានការកើនឡើងនៃតួរលេខប្រជាជនដែលស្លាប់ដោយសារការអត់ឃ្លាន និងជំងឺរាគត្បាតផ្សេងៗ ដែលបណ្តាលមកពីកង្វះអាហារូបត្ថម្ភ ។

*(ប្រិយមិត្តអ្នកស្តាប់ជាទីមេត្រី សូមក្រឡេកមើលចំណុចមួយទៀតស្តីពី)*

**តើការអត់ឃ្លានធ្វើឲ្យមនុស្សស្លាប់យ៉ាងដូចម្តេចខ្លះ?**

នៅពេលដែលការអត់អាហារចាប់ផ្តើមកើតមានឡើង ប្រជាជនកម្រនឹងស្លាប់ដោយសារការដាច់ពោះភ្លាមៗណាស់ ។ ផ្ទុយទៅវិញ ការស្លាប់ដោយសារការអត់ឃ្លានមានរូបភាពច្រើនយ៉ាង ។ ជាទូទៅ មនុស្សចាប់ផ្តើមបាក់កម្លាំងនៅពេលដែលអត់មានអាហារបរិភោគ ហើយជំងឺចាប់ផ្តើមរាតត្បាតនៅពេលដែលមនុស្សដើរស្វែងរកចំណីអាហារ ។ ជាមួយគ្នានេះដែរ មនុស្សមួយចំនួនបែរជាលែងស្គាល់នូវអាហារដែលអាចបរិភោគបាន នៅពេលដែលគ្រោះអត់ឃ្លានកើតមានឡើង ។ កត្តានេះអាចបណ្តាលឲ្យមនុស្សជួបប្រទះនូវបញ្ហាឈឺក្រពះ និងធ្វើឲ្យការអត់ឃ្លានកាន់តែមានសភាពធ្ងន់ធ្ងរឡើងៗ ។ បញ្ហាទាំងអស់នេះបានកើតឡើងជាក់ស្តែងនៅក្នុងប្រទេសកម្ពុជានៅក្នុងរបបខ្មែរក្រហម ។

សុខុមាលភាពរបស់ប្រជាជនកម្ពុជា បានចុះខ្សោយរួចទៅហើយបន្ទាប់ពីរងគ្រោះដោយសារសង្គ្រាមស៊ីវិលដែលអូសបន្លាយអស់រយៈពេល៥ឆ្នាំ ។ បន្ទាប់មក នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច ខ្មែរក្រហមបានបង្ខំប្រជាជនកម្ពុជារាប់សែននាក់ឲ្យផ្លាស់ទីលំនៅ ទៅកាន់ទីជនបទដាច់ស្រយាល ។ ការផ្លាស់ប្តូរលំនៅនេះ គឺជាហេតុបង្កឲ្យមានការរីករាលដាលនៃជំងឺឆ្លងផ្សេងៗ នៅពេលដែលប្រជាជនធ្វើការប្រាស្រ័យទាក់ទងជាមួយគ្នា ។ មិនតែប៉ុណ្ណោះទៀតសោត លក្ខខណ្ឌរស់នៅជាទូទៅរបស់ប្រជាជននៅក្នុងរបបខ្មែរក្រហមមានលក្ខណៈលំបាកយ៉ាងខ្លាំង ។ ខ្មែរក្រហមមិនបានផ្តល់ឲ្យប្រជា-ជនកម្ពុជានូវការរស់នៅដ៏សមរម្យមួយនោះទេ ។ ប្រជាជនកម្ពុជាស្ទើរគ្រប់តំបន់ត្រូវរស់នៅដោយកង្វះបង្គន់អនាម័យ ។ ប្រជាជនជាច្រើននាក់បានបាក់កម្លាំង ដោយសារការបង្ខំឲ្យធ្វើការធ្ងន់ធ្ងរ និងកង្វះខាតម្ហូបអាហារ ។ នៅពេលដែលប្រជាជនបាក់កម្លាំង និងពុំមានអាហារបរិភោគគ្រប់គ្រាន់ ប្រជាជនមិនអាចទៅដួតទឹកដុះសម្អាតខ្លួន ដើម្បីថែរក្សាអនាម័យខ្លួនប្រាណបានឡើយ ។ នេះជាហេតុបង្កឲ្យមានការចម្លងជំងឺកាន់តែខ្លាំងឡើង ។ នៅពេលមានជំងឺរាតត្បាតកើតឡើងម្តងៗ រួមផ្សំនឹងកង្វះខាតផ្នែកប្រព័ន្ធសុខាភិបាលនៅក្នុងរបបខ្មែរក្រហមផងនោះ ខ្មែរក្រហមជួបប្រទះបញ្ហាលំបាកក្នុងការកាត់បន្ថយល្បឿននៃការឆ្លងរាលដាលនៃជំងឺ ។

ក្រុមអ្នកជំនាញរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានធ្វើការប៉ាន់ប្រមាណកាលពីឆ្នាំ ២០០៩ថា នៅក្នុងរបបខ្មែរក្រហម ប្រជាជនកម្ពុជាចន្លោះពី៨សែន ទៅ ១លាន៣សែននាក់ បាន ស្លាប់ ដោយមិនទទួលរងនូវអំពើហិង្សានោះឡើយ ។ ប្រជាជនទាំងនោះបានស្លាប់ដោយកត្តាផ្សេងៗ ដែលមិនមែនជាបុព្វហេតុធម្មជាតិ ដូចជា ភាពចាស់ជរា ជាដើម ។ ប៉ុន្តែ ប្រជាជនភាគច្រើន បានស្លាប់ដោយសារការអត់ឃ្លានដោយផ្ទាល់ និងដោយប្រយោល ព្រមទាំងលក្ខខណ្ឌរស់នៅផ្សេងៗ ។ ទន្ទឹមនឹងនេះ វាមានភាពខុសគ្នាជាច្រើនអំពីគម្លាតនៃតួរលេខនៃចំនួនអ្នកដែលបានស្លាប់ដោយសារការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ។ បុព្វហេតុនៃការស្លាប់របស់ជនរងគ្រោះទាំងនោះមិនត្រូវបានកត់ត្រាត្រឹមត្រូវនោះទេ ។ ជាលទ្ធផល យើងអាចត្រឹមតែធ្វើការប៉ាន់ស្មានទៅលើចំនួនប្រជាជន ដែលបានស្លាប់ដោយសារការអត់ឃ្លានតែប៉ុណ្ណោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អ្នកប្រវត្តិសាស្ត្រខាងការអត់ឃ្លានម្នាក់បានឲ្យដឹងថា អត្រាអ្នកស្លាប់ដោយសារការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមមានកម្រិតខ្ពស់បំផុត បើប្រៀបធៀបនឹងចំនួនអ្នកដែលបានស្លាប់ដោយសារអត់ដំឡូងបារាំងបរិភោគរបស់ប្រជាជនអៀរឡង់ពីឆ្នាំ១៨៤៦ ដល់ឆ្នាំ១៩៥២ ។

ដូច្នេះ យើងអាចធ្វើការសរុបសេចក្តីមួយចំនួនបានទៅលើបញ្ហាអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម តាមរយៈព័ត៌មានដែលមានស្រាប់ថាៈ ទីមួយ ការអត់ឃ្លានអាចមកពីលទ្ធផលនៃសង្គ្រាមស៊ីវិលដែលបានកើតឡើងមុនរបបខ្មែរក្រហម និងគោលនយោបាយរបស់ខ្មែរក្រហមដែលធ្វើឲ្យការអត់ឃ្លានកាន់តែមានសភាពធ្ងន់ធ្ងរជាងពេលដែលខ្មែរក្រហមមិនទាន់ដាក់ជាគោលនយោបាយទៅទៀត ។ ទីពីរ ការស្លាប់ដោយសារជំងឺ និងការស្លាប់ដោយសារការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធ ពោលគឺជំងឺភាគច្រើនដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមបណ្តាលមកពីកង្វះខាតម្ហូបអាហារ ។ ទីបី ខ្មែរក្រហមមិនបានចាត់វិធានការ ឬកែប្រែគោលនយោបាយរបស់ខ្លួននោះទេ នៅពេលដែលមានការអត់ឃ្លានកើតឡើង ។ ម្យ៉ាងវិញទៀត មូលដ្ឋាននៃការដឹកនាំរបស់ខ្មែរក្រហមបែរជាធ្វើឲ្យគោលនយោបាយរបស់ខ្លួនកាន់តែតឹងរឹងជាងមុន ដែលបង្កឲ្យគ្រោះអត់ឃ្លានធ្លាក់ក្នុងសភាពធ្ងន់ធ្ងរឡើងៗ ។ ទីបួន យើងអាចនិយាយបានថា ប្រជាជនកម្ពុជារាប់សែននាក់បានស្លាប់បាត់បង់ជីវិតដោយសារពុំមានអាហារបរិភោគគ្រប់គ្រាន់ ។ ជាលទ្ធផល ប្រជាជនកម្ពុជាប្រហែលជាមួយលាននាក់បានស្លាប់ដោយសារតែមូលហេតុផ្សេងៗដែលពាក់ព័ន្ធនឹងគ្រោះអត់ឃ្លាន ។ ជាសរុប យើងអាចសន្និដ្ឋានបានថា ភាគរយនៃចំនួនប្រជាជនដែលបានស្លាប់ដោយសារការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមជាភាគរយដែលច្រើនជាងគេបំផុតនៃប្រជាជនដែលបានស្លាប់ដោយសារការអត់ឃ្លាននៅក្នុងសតវត្សទី២០ ។

(ជាបន្តទៅនេះ យើងខ្ញុំសូមលើកយកអត្ថបទមួយក្រោមចំណងជើងថា «នៅពេលដែលការអត់ឃ្លានចូលមកដល់» ចេញផ្សាយដោយទស្សនាវដ្តី«ស្វែងរកការពិត»របស់មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ ៣០ ខែមិថុនា ឆ្នាំ២០០២ សរសេរដោយ សាន់ កល្យាណ ។)

# នៅពេលដែលការអត់ឃ្លានចូលមកដល់

នៅថ្ងៃទី១៧ មេសា ១៩៧៥ អ្នកស្រី គ្រួច សំអាន ត្រូវអង្គការខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ ឲ្យទៅរស់នៅខេត្តពោធិសាត់ ។

ពោធិសាត់គឺជាខេត្តមួយស្ថិតនៅទិសពាយ័ព្យនៃប្រទេសកម្ពុជា សម្បូរព្រៃភ្នំនិងតំបន់មួយចំនួន ផុតទៅដោយមេរោគគ្រុនចាញ់ និងខ្វះខាតទឹកនៅរដូវប្រាំង ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទឹកដីខេត្តពោធិសាត់ត្រូវបានខ្មែរក្រហមហៅថាដីខ្លាញ់ ។ កម្ពុជាប្រជាធិបតេយ្យបានបញ្ចូលខេត្តពោធិសាត់ទៅក្នុងភូមិភាគពាយ័ព្យ និងបែកចេញជាពីរតំបន់គឺ តំបន់៦ និងតំបន់៧ ។ ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញ ត្រូវជម្លៀសឲ្យទៅរស់នៅតាមបណ្ដាខេត្តនានា រួមមានខេត្តខេត្តពោធិសាត់និងបាត់ដំបង ។ ប្រជាជនទីក្រុង ត្រូវបានខ្មែរក្រហមដាក់ឈ្មោះថា ប្រជាជន១៧មេសា ឬប្រជាជនថ្មី ។ នៅទូទាំងប្រទេសកម្ពុជា ទីកន្លែងដែលប្រជាជន១៧មេសាត្រូវលត់ដំខ្លាំងបំផុតគឺខេត្តពោធិសាត់ ។ ដោយសារទឹកដីខេត្តពោធិសាត់ជាទឹកដីពិបាករស់នៅផង និងដោយសារការគ្រប់គ្រងមានសភាពរឹតបន្តឹងជាងតំបន់នានាផងនោះ បានធ្វើឲ្យប្រជាជនមួយចំនួនធំត្រូវស្លាប់នៅទីនោះ ។




នៅក្នុងខេត្តពោធិសាត់ ក្រុមគ្រួសាររបស់អ្នកស្រី គ្រួច សំអាន និងគ្រួសារអ្នកជម្លៀសជាច្រើនទៀត ត្រូវរស់នៅកណ្ដាលវាលព្រៃរបោះនិងវាលស្មៅដ៏ធំល្វឹងល្វើយ គឺជាតំបន់ដែលមិនធ្លាប់មានមនុស្សរស់នៅពីមុនមក ។ តំបន់ដែលអ្នកស្រីរស់នៅមានឈ្មោះថា សហករណ៍ស្វាយស ស្ថិតនៅក្នុងឃុំស្វាយស ស្រុកក្រគរ ខេត្តពោធិសាត់ ។ ប្រជាជនដែលរស់នៅសហករណ៍ស្វាយស សុទ្ធសឹងជាអ្នក១៧មេសាទាំងអស់ ។ សហករណ៍ ស្វាយសបែកចេញ ជាច្រើនកង ហើយសមាជិកគ្រួសារនីមួយៗត្រូវរស់នៅបែកខ្ញែកគ្នាទៅធ្វើការតាមកងផ្សេងៗ ។ ខ្លួនអ្នកស្រីនិងប្អូនស្រីម្នាក់ត្រូវទៅរស់នៅក្នុងកងចល័ត ។ ប្អូនប្រុសម្នាក់ត្រូវទៅធ្វើការនៅក្នុងកងកុមារ ។ ប្អូនប្រុសពៅ២នាក់ទៀតដែលជាកូនក្មេង ត្រូវទៅនៅក្នុងកងកុមារ ។ ចំណែកឪពុកម្ដាយរបស់អ្នកស្រី ត្រូវរស់នៅក្នុងសហករណ៍ ។ នៅឆ្នាំ១៩៧៦ ឪពុកម្ដាយរបស់អ្នកស្រីបានស្លាប់ ដោយសារតែការអត់ឃ្លាន ។ អ្នកស្រីបានបញ្ជាក់ថា នៅដង្ហើមចុងក្រោយរបស់ឪពុកម្ដាយអ្នកស្រីគឺគាត់ស្រែករកអ៊ីហូប ព្រោះគាត់ឃ្លានណាស់! ឃ្លានណាស់! ។ ចំណែកប្អូនប្រុសម្នាក់របស់អ្នកស្រីដែលកាលណោះនៅជាកុមារនៅឡើយ ក៏បានស្លាប់ដោយសារតែទារុណកម្មពីសំណាក់កុមារដូចគ្នា ។

នៅសហករណ៍ស្វាយស អ្នកស្រី គ្រួច សំអាន មានប្រសាសន៍ថា នៅពេលទៅរស់នៅទីនោះដំបូង ខ្មែរក្រហមឲ្យប្រជាជនហូបបាយឆ្អែតជានិច្ច ។ ក្នុងប្រជាជនម្នាក់បានទទួលរបបអង្ករ១កំប៉ុងកន្លះក្នុងមួយថ្ងៃ ។ ពេលវេលាឆ្អែតស្កប់ស្កល់នេះមានរយៈពេលតែ១ខែកន្លះប៉ុណ្ណោះ របបអង្ករក៏ចាប់ផ្ដើមបន្ថយមកនៅត្រឹម១កំប៉ុង២នាក់ក្នុង១ថ្ងៃ បន្ទាប់មក១កំប៉ុង៣នាក់ បន្ទាប់មក១កំប៉ុង៤នាក់ បន្ទាប់មកទៀត១កំប៉ុង៨នាក់ រហូតដល់ទីបំផុតគឺបបរ១ខ្ទះដាក់អង្ករតែ១កំប៉ុងប៉ុណ្ណោះសម្រាប់មនុស្សមួយសហករណ៍ ។ ដើមឆ្នាំ១៩៧៦ របបអាហារសម្រាប់ប្រជាជននៅសហករណ៍ស្វាយសគឺអង្ករ១កំប៉ុងសម្រាប់បបរ១ខ្ទះត្នោត ។ របបសម្រាប់មនុស្សម្នាក់ៗគឺបបរមួយវែកគ្រឡោកដែលចុងកៅផ្ទះបាយសមូហភាពដួសដាក់ចូលក្នុងចាន ។ ម៉្លោះហើយ ប្រជាជនដែលរស់នៅក្នុងសហករណ៍ស្វាយសទាំងមូលត្រូវជួបប្រទះនឹងការអត់ឃ្លានយ៉ាងខ្លាំង ។ អ្នកស្រីមានប្រសាសន៍ថា ដោយសាររបបអាហារហូបមិនឆ្អែត មនុស្ស

ម្នាក់ៗខិតខំដើរបេះពោចបន្លែបន្លា ស្លឹកឈើព្រៃ រកចាប់ត្រី ក្តាមខ្យង សត្វល្អិតល្អោចដែលអាចហូបបាន ដើម្បីយកមកបំពេញក្រពះ ។ ប៉ុន្តែរបស់ទាំងអស់នេះមិនអាចបំបាត់ភាពស្រេកឃ្លានរបស់ប្រជាជនទេ ។ នៅពេលដែលការអត់ឃ្លានឈានដល់ដំណាក់កាលខ្លាំងក្លាបំផុត ប្រជាជនមួយចំនួនបានបរិភោគសាច់មនុស្សដូចគ្នា ជួនកាលគឺជាសាច់របស់សមាជិកក្នុងគ្រួសារខ្លួនតែម្តង ។ ប្រសិនបើនៅក្នុងគ្រួសារមួយមានសមាជិកណាម្នាក់ឈឺជិតស្លាប់ សមាជិកដទៃទៀតមិនទុកឲ្យអ្នកជំងឺស្លាប់ទាន់ទេ គេនឹងសម្លាប់អ្នកជំងឺនោះធ្វើជាម្ហូបសម្រាប់គ្រួសារ ប៉ុន្តែសកម្មភាពនេះត្រូវធ្វើដោយលួចលាក់មិនឲ្យអ្នកដទៃដឹងឡើយ ព្រោះអង្គការហាមផ្តាច់មិនឲ្យមានការបរិភោគជាឯកជនក្បត់សមូហភាពទេ ។ ប្រសិនបើនរណាម្នាក់ឬគ្រួសារណាមួយត្រូវបានរកឃើញថាលួចហូបក្បត់សមូហភាព នឹងត្រូវមានទោសដល់ស្លាប់ ។ មានមនុស្សមួយចំនួនទៀតបានលួចគាស់សាកសពដែលទើបតែកប់ថ្មីៗ ដើម្បីយកសាច់ធ្វើជាអាហារ ។ អ្នកស្រីបានបញ្ជាក់ឲ្យដឹងថា នៅក្នុងកងទី២០ នៃសហករណ៍ស្វាយស ស្ត្រីមេម៉ាយម្នាក់បានសម្លាប់កូនរបស់គាត់ដែលឈឺជិតស្លាប់ ដើម្បីធ្វើសម្លទទួលទាន ។ នៅក្នុងកងទី១៩ ពីរនាក់ប្តីប្រពន្ធបានសម្លាប់កូនរបស់ខ្លួនចំនួន២នាក់ជាបន្តបន្ទាប់គ្នាធ្វើជាអាហារ ។ នៅក្នុងកងទី២៣ កូនប្រុស៣នាក់បានសម្លាប់ឪពុករបស់ខ្លួនដែលជិតស្លាប់ ហើយព្រលះយកសាច់ឪពុកទុកសម្រាប់បរិភោគ ។ ករណីមួយទៀត អ្នកស្រី គ្រួច សំអាន បញ្ជាក់ថា បានកើតឡើងចំពោះប្អូនប្រុសរបស់អ្នកស្រីផ្ទាល់តែម្តង ។ ក្នុងអំឡុងខែ៥ ឆ្នាំ១៩៧៦ ជាដំណាក់កាលដែលរបបអាហារត្រូវបន្ថយរហូតដល់បបរ១ខ្ទះមានតែអង្ករ១កំប៉ុង ។ ដោយអត់ឃ្លានខ្លាំងពេក ប្អូនប្រុសរបស់អ្នកស្រីបានទៅសុំរស់នៅក្នុងមណ្ឌលកុមាររបស់សហករណ៍ទឹកជុំដែលស្ថិតនៅចម្ងាយប្រមាណ២០គីឡូម៉ែត្រពីសហករណ៍ស្វាយស ប៉ុន្តែត្រូវប្រធានមណ្ឌលកុមារបដិសេធ មិនតែប៉ុណ្ណោះថែមទាំងត្រូវកុមារនៅក្នុងមណ្ឌលនោះរករឿងវាយតប់រហូតមានរបួសនៅកំភួនជើងថែមទៀត ។ រំលងបានមួយថ្ងៃ ប្អូនប្រុសរបស់អ្នកស្រីក៏ស្លាប់ដោយសារជំងឺតេតាណូសមុខរបួសនោះ ។ នៅពេលដែលអ្នកស្រីយកសពប្អូនប្រុសទៅកប់រួចថ្មីៗ ស្រាប់តែមានមនុស្សលួចគាស់សពនោះយកទៅកាប់ចិញ្ច្រាំធ្វើជាម្ហូបអាហារ ។ ១សប្តាហ៍ក្រោយមក អ្នកស្រីបានស្គាល់មុខអ្នកដែលលួចគាស់សាកសពប្អូនប្រុសរបស់គាត់ នៅពេលដែលជននោះយកសាច់មកអាំង ហើយត្រូវឈ្លបសង្ស័យក៏ឆែករកឃើញពាងដាក់សាច់មនុស្សនៅលើផ្ទះ ។ ជនល្មើសនោះគឺជាកុមារម្នាក់ដែលមានអាយុទើបតែជាង១០ឆ្នាំ ។

យប់មួយនាឆ្នាំ១៩៧៧ នៅឯសហករណ៍កោះជុំ ពេលដែលមនុស្សទាំងអស់ក្នុងសហករណ៍កំពុងតែប្រជុំជីវភាព ស្រាប់តែមានភាពផ្អើលឆោឡោដោយសារមានមនុស្សព្រៃមកចាប់ក្មេងយកទៅ ។ បន្ទាប់ពីឈ្លបព័ទ្ធចាប់បាន ជនល្មើសបានសារភាពថា ពីមុនខ្លួនជាកងទ័ពរំដោះ ហើយនៅក្រោយថ្ងៃ



សាច់សាលោហិតជនរងគ្រោះក្រោមរបបខ្មែរក្រហម

១៧មេសា ឆ្នាំ១៩៧៥ ក៏ត្រូវរំសាយឲ្យទៅធ្វើការនៅក្នុងកង ដឹកជញ្ជូន បានតែមួយរយៈខ្លីក៏គេចខ្លួនទៅរស់នៅក្នុងព្រៃហូត ។ ក្រុមមនុស្សព្រៃនេះមានគ្នា៧នាក់ គឺជាក្រុមមនុស្សដែលគេច ពីការគ្រប់គ្រងរបស់របបខ្មែរក្រហម ។ ម្ហូបអាហាររបស់ក្រុម មនុស្សព្រៃនេះ គឺជាសាច់មនុស្សដែលគេតែងតែចូលមកលប លួចចាប់ពីភូមិយកទៅ ។

នៅក្នុងសៀវភៅកំណត់ហេតុរបស់សមមិត្ត ញ៉ុក សាខុន ជាកម្មាភិបាលខ្មែរក្រហមមួយរូប បានសរសេរពាក្យស្លោក មួយឃ្លាថា «សេចក្ដីអត់ឃ្លានជារោគមានអានុភាពជាងគេទាំង ឡាយ» ។ ជាមួយនឹងទ្រឹស្ដីនេះ ខ្មែរក្រហមពិតជាយល់ច្បាស់ ណាស់ថា អ្វីដែលមនុស្សត្រូវការបំផុតសម្រាប់ជីវិតគឺអាហារ ។ បើគ្មានអាហារ មនុស្សមិនអាចរស់បានទេ ។ ទោះបីជាយល់



**ធ្វើដំណើរមកស្រុកកំណើតវិញនៅឆ្នាំ១៩៧៩**

ច្បាស់យ៉ាងនេះក៏ដោយ ក៏ខ្មែរក្រហមបែរជាផ្ដល់អាហារឲ្យ ប្រជាជនតិចបំផុត ក្នុងខណៈដែលខ្លួនបង្ខំឲ្យប្រជាជនធ្វើការច្រើន បំផុត ។ នៅពេលដែលបរិមាណអាហារមិនមានតុល្យភាពនឹង ទំហំនៃការងារ ប្រជាជនត្រូវទទួលរងនូវគ្រោះទុរ្ភិក្ស បាក់កម្លាំង និងការរាតត្បាតពីជំងឺផ្សេងៗ ដែលទាំងអស់នេះជាមូលហេតុ នាំដល់ការស្លាប់បាត់បង់ជីវិតប្រជាជនអស់ជាច្រើនសែននាក់ ។ សម្រាប់សហករណ៍ស្វាយសនៅក្នុងឃុំស្វាយស ស្រុកក្រគរ ខេត្តពោធិសាត់ អ្នកស្រី គ្រួច សំអាន បានឲ្យដឹងថា គ្រាន់តែ នៅក្នុងកងទី២០ដែលអ្នកស្រីរស់នៅ ពីដំបូងមានមនុស្ស ប្រមាណ២០០នាក់ ក្រោយមកនៅសល់ប្រហែលតែ៣៥នាក់ ប៉ុណ្ណោះ ។ គ្រួសាររបស់អ្នកស្រីដែលមានសមាជិក៨នាក់ នៅសល់តែ៤នាក់ប៉ុណ្ណោះដែលរស់រានមានជីវិត ។

ប៉ុល ពត លេខាបក្សកុម្មុយនិស្តកម្ពុជា និងជារដ្ឋមន្ត្រីទី១ នៃកម្ពុជាប្រជាធិបតេយ្យ តែងតែប្រកាសក្អេងក្អាងប្រាប់សកល លោកថា នៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលកម្ពុជាប្រជា-ធិបតេយ្យ ប្រជាជនកម្ពុជាមានជីវភាពរស់នៅសម្បូរសប្បាយរុងរឿង មានអាហារហូបចុកយ៉ាងបរិបូរណ៍ មានលំនៅឋានសមរម្យ មាន សម្លៀកបំពាក់គ្រប់គ្រាន់ មានសេវាសង្គមយ៉ាងប្រសើរ មាន ស្មារតីបដិវត្តខ្ពស់ ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន មិនពឹងពាក់ បរទេស និងមានភាពស្មើៗគ្នា ។ ធាតុពិតនៅពីក្រោយពាក្យសម្ដី ទាំងនេះ ប្រជាជនរស់នៅប្រៀបបានទាសករនៅក្នុងខ្ទមតូចៗ ដែលមិនស័ក្ដិសមជាផ្ទះ បរិភោគអាហារនិងធ្វើការងារដូច សត្វធាតុ ។ ប្រទេសកម្ពុជាទាំងមូលត្រូវប្រែក្លាយទៅជាគុកឥត ជញ្ជាំង ហើយប្រជាជនទាំងអស់ក្លាយទៅជាអ្នកទោសរបស់ គុកនេះ ។

ការស្លាប់ដែលបណ្ដាលមកពីអត់អាហារ ធ្វើការបាក់កម្លាំង រស់នៅគ្មានផាសុក សេវាសង្គមកិច្ចនិងសុខាភិបាលមិនត្រឹមត្រូវ បូករួមទាំងការកាប់សម្លាប់ប្រជាជនយ៉ាងច្រើនសន្ធឹកសន្ធាប់ ទៀត បានធ្វើឲ្យចំនួនមនុស្សស្លាប់នៅក្នុងរបបកម្ពុជាប្រជា ធិបតេយ្យកើនដល់ជិតពាលាននាក់ ស្មើនឹងជាង៤០ភាគរយ នៃចំនួនប្រជាជនទាំងអស់ ។

**សាន់ កល្យាណ**

ប្រិយមិត្តអ្នកស្តាប់ជាទីមេត្រី ការផ្សាយនៅវគ្គក្រោយ យើងនឹងធ្វើការពិនិត្យ ថាតើដំណើរការនៃការអត់ឃ្លានប្រព្រឹត្តទៅយ៉ាងដូចម្តេច ហើយការអត់ឃ្លានអាចបង្កឲ្យមានការស្លាប់កាន់តែច្រើនដែរឬទេ ដោយធ្វើការប្រៀបធៀបពីការវិវត្តន៍នេះជាមួយនឹងការអត់ឃ្លានដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ។

មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រិយមិត្តអ្នកស្តាប់ដែលបានតាមដានស្តាប់ការផ្សាយរបស់យើងខ្ញុំ និងសូមថ្លែងអំណរគុណចំពោះស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ ដែលបានផ្តល់ស៊ីឌីយោថតសម្លេង ។

ប្រសិនបើប្រិយមិត្តអ្នកស្តាប់ចង់ចូលរួមផ្តល់ជាមតិយោបល់ សួរសំណួរ ឬមានចម្ងល់ផ្សេងៗនៅក្នុងកម្មវិធីសូមសរសេរជាលិខិតផ្ញើរមកកាន់ លោក ម៉ែន ពិចិត្រ អ្នករៀបចំកម្មវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានអាសយដ្ឋានផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ឬប្រអប់ សំបុត្រលេខ ១១១០ រាជធានីភ្នំពេញ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣-២១១-៨៧៥ ឬទូរសារលេខ ០២៣-២១០-៣៥៨ ។ សូមអរគុណ ។